# ការរក្សាការពារក្នុងរឿងក្ដីរដ្ឋប្បវេណី

# ផ្នែក 1

# ប្រភេទនៃការរក្សាការពារក្នុងរឿងក្ដីរដ្ឋប្បវេណី

# សេចក្ដីពន្យល់បន្ថែម

ថ្ងៃទី 21 ខែមករា ឆ្នាំ2018

ជំនាញការនៃគម្រោងអភិវឌ្ឍន៍ប្រព័ន្ធច្បាប់

MAEDA Yuta

- Slide 3

ការចាត់ចែងរក្សាការពារនៅក្នុងការអនុវត្តចំពោះអចលនវត្ថុ (ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា429) គឺជានីតិវិធីពិសេសដែលត្រូវបានគេទទួលស្គាល់នៅក្នុងនីតិវិធីនៃការអនុវត្ត ហើយមិនមែនជាការរក្សាការពារក្នុងរឿងក្តីរដ្ឋប្បវេណីទេ។ នៅក្នុងនីតិវិធីមួយនេះពុំមានបណ្តឹង ដូច"អង្គសេចក្តី" នៃការរក្សាពារពារក្នុងរឿងក្តីរដ្ឋប្បវេណីទេ។ ប៉ុន្តែ នៅច្បាប់ស្តីពីនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល មាត្រា ២១ ចែងថា ក្រោយពីមានពាក្យបណ្តឹងទាក់ទងនឹងឋានៈបុគ្គល តុលាការអាចបង្គាប់ឲ្យមានរក្សាការពារក្នុងរឿងក្តីរដ្ឋប្បវេណីដោយឆន្ទានុសិទ្ធិបាន។ ដូច្នេះ ហើយរក្សាការពារដែលតុលាការបានធ្វើនៅក្នុងករណីនេះ នឹងក្លាយទៅជារក្សាការពារនៃរឿងក្តីរដ្ឋប្បវេណីប្រភេទណាមួយ។

ដោយសារតែ រឿងក្តីដែលបានកើតមានឡើង (រឿងក្តីអនុវត្ត និង បណ្តឹងទាក់ទងនឹងឋានៈបុគ្គល) គឺរឿងក្តីដោយឡែក ដូច្នេះ ទោះបីជាក្នុងករណីណាមួយក្នុងចំណោមរក្សាការពារដែលបានលើកឡើងខាងលើនេះក៏ដោយ ក៏តុលាការត្រូវចេញដីកាសម្រេចដាច់ដោយឡែកដែរ។

- Slide 7

តុលាការមិនត្រឹមតែអាចបង្គាប់ឲ្យធ្វើសកម្មភាពជាបណ្តោះអាសន្នតែប៉ុណ្ណោះទេ ថែមទាំងអាចបង្គាប់មិនឲ្យធ្វើសកម្មភាពជាបណ្តោះអាសន្នបានផងដែរ។ ជាពិសេស គឺការចាត់ចែងនេះ គឺជាការចាត់ចែងជាបណ្តោះអាសន្នដែលធ្វើទៅដូចជាស្ថានភាព (មួយផ្នែក) នៃការឈ្នះក្តីនៅក្នុងបណ្តឹងអង្គសេចក្តីដែរ ពោលគឺមានន័យថា ធ្វើការអនុវត្តដោយមិនចាំបាច់រង់ចាំបណ្តឹងអង្គសេចក្តី។ ហេតុនេះ ភាគីមិនអាចដាក់ពាក្យសុំណាដែលមើលទៅយល់ថា តុលាការនៃបណ្តឹង
អង្គសេចក្តីមិនអាចទទួលស្គាល់បានទេ។